**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**

-លេខ ១០ "ខ"

-ចុះថ្ងៃទី ០៦ ខែមករា ឆ្នាំ២០២០

-សំណុំរឿងរដ្ឋប្បវេណីលេខ ២០៩៥

-ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ វេលាម៉ោង១៤នាទី នៅសាលសវនាការទី៣ លើសំណុំរឿងរដ្ឋប្បវេណីលេខ២០៩៥ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

-លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

-ដើមចោទឈ្មោះ [redacted] **គុណា** ភេទប្រុស កើតថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៨៣ ជនជាតិខ្មែរ មុខរបរ ជាងប៉ះកង់ មានទីលំនៅសព្វថ្ងៃ[redacted] ឪពុកឈ្មោះ[redacted] ខេង (ស) ម្តាយឈ្មោះ[redacted]មួយ (រ) ប្រពន្ធឈ្មោះ[redacted] **ខចិត្ត៉ា** មានកូន០១នាក់ មានលោក[redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

-ចុងចម្លើយឈ្មោះ[redacted] **ខចិត្ត៉ា** ភេទស្រី កើតថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៨៣ ជនជាតិខ្មែរ មុខរបរកម្មការិនី មានទីលំនៅសព្វថ្ងៃ[redacted] ភ្នំពេញ ឪពុកឈ្មោះ[redacted]សារ៉ាន់ (រ) ម្តាយឈ្មោះ[redacted]សាម៉ា (រ) ប្តីឈ្មោះ [redacted]**គុណា** មានកូន០១នាក់ ។

## I. **អង្គហេតុ និងចំណុចវិវាទ**

ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

-ប្តឹងសុំលែងលះប្រពន្ធឈ្មោះ[redacted] **ខចិត្ត៉ា**

-ប្រគល់អំណាចមេបាលើកូន០១ នាក់ឈ្មោះ[redacted]រ៉ាលីន ភេទស្រី កើតថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ទៅឲ្យភាគីចុងចម្លើយ ។

-ផ្តល់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនតាមលទ្ធភាព។

ខ.ការពន្យល់ត្រួសៗអំពីរឿងក្តី

-ក្នុងរឿងនេះដើមចោទសុំឲ្យតុលាការចេញសាលក្រមដូចចំណុច(ក)ខាងលើ ដោយហេតុថា៖ គូភាគីរស់នៅមិនចុះសំរុងគ្នា ជាហេតុធ្វើឲ្យខ្លួនអស់មនោសញ្ចេតនាជាប្តីប្រពន្ធ ។ គូភាគីរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៩ មានសំបុត្រអាពាហ៍ពិពាហ៍លេខ១៨៤ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ ។ ការរស់នៅជាមួយគ្នាមានកូន០១នាក់ឈ្មោះ[redacted]រ៉ាលីន ភេទស្រី កើតថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ។

គ.អង្គហេតុដែលអះអាងដោយដើមចោទ

-ដើមចោទឈ្មោះ[redacted] **គុណា** បានថ្លែងការណ៍ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា៖ខ្លួនប្តឹងសុំលែងលះពីប្រពន្ធឈ្មោះ[redacted] **ខចិត្ត៉ា** ដោយហេតុថា រស់នៅមិនចុះសំរុងគ្នាធ្វើឲ្យខ្លួនអស់មនោសញ្ចេតនាជាប្តី

ប្រពន្ធ។ ហើយបានបែកលំនៅពីគ្នាតាំងពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ រហូតដល់សព្វថ្ងៃ ខ្លួនបានរៀបការនៅថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០០៩ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់លេខ១៨៤ សៀវភៅអាពាហ៍ពិពាហ៍ លេខ០៤/២០១៤ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់ឬស្សីកែវ ។ ការរស់នៅជាមួយគ្នាមានកូន០១នាក់ឈ្មោះ[redacted]រ៉ាលីន ភេទស្រី កើតថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ខ្លួនប្រគល់អំណាចមេបាលើកូន០១នាក់នេះទៅឲ្យចុងចម្លើយគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សា សព្វថ្ងៃកូនរស់នៅជាមួយចុងចម្លើយ ហើយប្រាក់ចាំបាច់សម្រាប់ចិញ្ចឹមកូនខ្លួនផ្តល់តាមលទ្ធភាព។ ខ្លួនបានរស់នៅបែកគ្នាតាំងពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ រហូតដល់សព្វថ្ងៃ ទ្រព្យដើមគ្មាន ទ្រព្យរួមគ្មាន និងបំណុលគ្មាន។

**ឃ.អង្គហេតុដែលអះអាងដោយចុងចម្លើយ**

-ក្រឡាបញ្ជីអានចម្លើយចុងចម្លើយឈ្មោះ[redacted] **ខចិត្តរ៉ា** បានថ្លែងការណ៍នៅនីតិវិធីត្រៀមទាញហេតុផលកាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ថា: ការសុំលែងលះ,ការប្រគល់អំណាចមេបាលើកូន០១នាក់ និងសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន ខ្លួនឯកភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលថ្លែងខាងលើទាំងស្រុង ។ ខ្លួននិងដើមចោទបានរស់នៅបែកគ្នាតាំងពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ រហូតដល់សព្វថ្ងៃ ទ្រព្យដើមគ្មាន ទ្រព្យរួមគ្មាន និងបំណុលគ្មាន។

-លោក[redacted]មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ បានថ្លែងការណ៍បញ្ជាក់ថា: ខ្លួនឯកភាពលើសេចក្តីថ្លែងការណ៍របស់គូភាគី សុំតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី ។

**ង.ចំណុចវិវាទ និងចំណុចគ្មានវិវាទ**

១/. ចំណុចវិវាទ៖ គូភាគីឯកភាពលែងលះ,ការប្រគល់អំណាចមេបាលើកូន០១នាក់ និងសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន។

២/. ចំណុចគ្មានវិវាទ៖គ្មាន

## II.ការពិនិត្យភស្តុតាង

**១ ភស្តុតាងជាឯកសាររបស់ដើមចោទ**

១.១.សំបុត្រអាពាហ៍ពិពាហ៍លេខ១៨៤ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់ ឬស្សីកែវ និងឯកសារភ្ជាប់ ។

**២ ភស្តុតាងជាឯកសាររបស់ចុងចម្លើយ ៖ គ្មាន ។**

## សំអាងហេតុ

១- ផ្អែកតាមលទ្ធផលសាកសួរនិងពិនិត្យភស្តុតាង នៅនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖ ដើមចោទឈ្មោះ[redacted] តុលា និងចុងចម្លើយឈ្មោះ[redacted] វិចិត្តរ៉ា បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៩ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។ គូភាគីរួមរស់ជាមួយគ្នាមិនចុះសំរុង ធ្វើឲ្យដើមចោទរស់មានទោសញ្ញេតនាពីចុងចម្លើយ ហើយគូភាគីបានបែកលំនៅពីគ្នាតាំងពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ រហូតដល់សព្វថ្ងៃ ។ គូភាគីបង្កើតបានកូន០១នាក់ឈ្មោះ[redacted]រ៉ាលីន ភេទស្រី កើតថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ។

២-គូភាគីបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ១៨៤ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់ ឬស្សីកែវ ។



Scanned with CamScanner

៣-តុលាការបានធ្វើការផ្សះផ្សាគូភាគីគ្រប់ដំណាក់កាលនៃនីតិវិធី តែគូភាគីពុំព្រមសះជានិងគ្នាវិញឡើយ។ គូភាគីបានឯកភាពលែងលះដោយស្ម័គ្រចិត្តពុំមានការបង្ខិតបង្ខំពីភាគីណាឡើយ។ ដូចនេះគប្បីតុលាការសម្រេចឲ្យគូភាគីលែងលះតាមការព្រមព្រៀងរបស់គូភាគី ។

៤-គូភាគីមានកូន០១នាក់ឈ្មោះ [redacted] រ៉ាលីន ភេទស្រី កើតថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ។ ភាគីដើមចោទបានប្រគល់អំណាចមេបាលើកូន០១នាក់នេះទៅឲ្យភាគីចុងចម្លើយ និងផ្តល់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនតាមលទ្ធភាព ភាគីចុងចម្លើយក៏បានឯកភាពផងដែរ ។ ដូច្នេះគប្បីតុលាការសម្រេចតាមឆន្ទៈរបស់គូភាគី។

៥-គូភាគីពុំមានទ្រព្យដើម ទ្រព្យសម្បត្តិរួម និងពុំមានបំណុលឡើយ។

៦- ប្រាក់ប្រដាប់ក្តី គប្បីដាក់បន្ទុកលើគូភាគី ។

## សេចក្តីសម្រេចបញ្ចប់

១. ឲ្យដើមចោទឈ្មោះ [redacted] តុលា និងចុងចម្លើយឈ្មោះ [redacted] ខចិត្តរ៉ា លែងលះពីគ្នាតាមមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី ។

២.កំណត់យកភាគីចុងចម្លើយឈ្មោះ [redacted] ខចិត្តរ៉ា ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] រ៉ាលីន ភេទស្រី កើតថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ។

ភាគីដែលពុំមានអំណាចមេបាលើកូន មានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងជាមួយកូននេះបាន ។ ភាគីដែលមានអំណាចមេបា ត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត តាមមាត្រា១០៣៧ និងមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់គូភាគី។

៤.សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ។

គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល០១ខែ(មួយ)ខែគិតចាប់ពីថ្ងៃបានទទួលសាលក្រមនេះ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]

---

**បានឃើញ**

**ចៅក្រម**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃច័ន្ទ១២កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ពស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]